# សិក្ខាសាលាតូចស្ដីពី ការតាក់តែងពាក្យបណ្ដឹង (រឿងក្ដីប្រាក់កម្ចី)

# តើកូនក្តី X អាចទាមទាមចំពោះ Y អ្វីខ្លះ?

- អំពីប្រាក់ 10.000$ (កម្ចី 1.12.2012)
  1. ការទាមទារឲ្យសងប្រាក់ដើមចំនួន 10.000$
  2. ការទាមទារការប្រាក់ 15% / ឆ្នាំ
     - អំឡុងពេលគឺ 1.12.2012~30.11.2013
  3. ការទាមទារការប្រាក់យឺតយ៉ាវតាមការព្រមព្រៀងក្រោយហួសពេលសង
     - អំឡុងពេលគឺ 1.12.2013~រហូតដល់ថ្ងៃសងគ្រប់ចំនួន
- អំពីប្រាក់ 5000$ (កម្ចី 15.3.2013)
  1. ការទាមទារឲ្យសងប្រាក់ដើមចំនួន 5000$
  2. ការទាមទារការប្រាក់យឺតយ៉ាវតាមច្បាប់កំណត់ក្រោយហួសពេលសង (អំឡុងពេលគឺ ថ្ងៃដែលជាអំឡុងពេលសមរម្យក្រោយការដាស់តឿនបានកន្លងផុត~រហូតដល់ថ្ងៃសងរួច)

# តើកូនក្តី X អាចទាមទាមចំពោះ Y អ្វីខ្លះ ? ( បន្ត )

- ភាពខុសគ្នានៃការប្រាក់ និង ការប្រាក់ឃើតយ៉ាវ
- តើអាចទាមទារ សំណងជម្ងឺចិត្ត បានដែរឬទេ ?

# អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ និង ជាមូលហេតុនៃការទាមទារ
# 1—①ការទាមទារឲ្យសងប្រាក់ដើម 10.000$

1. ការព្រមព្រៀងខ្ចីប្រាក់រវាង X･Y
   - នៅថ្ងៃទី1 ខែ12 ឆ្នាំ2012 X និង Y បានព្រមព្រៀងគ្នាថា X ឲ្យ Y ខ្ចីប្រាក់ចំនួន 10.000$ ហើយ Y នឹងសងប្រាក់នេះមកវិញនៅពេលក្រោយ។
   - បញ្ជាក់អត្តសញ្ញាណដោយភាគី កាលបរិច្ឆេទ និង ចំនួនទឹកប្រាក់។
2. ការព្រមព្រៀងអំពីពេលសងរវាង X･Y
   - នៅថ្ងៃទី1 ខែ12 ឆ្នាំ2012 X និង Y បានព្រមព្រៀងថា យកថ្ងៃទី30 ខែ11 ឆ្នាំ2013 ជាពេលសងនៃចំណុចទី 1។
3. ការប្រគល់ប្រាក់ X→Y
   - នៅថ្ងៃទី1 ខែ12 ឆ្នាំ2012 X បានប្រគល់ប្រាក់ចំនួន 10.000$ ទៅ Y ដោយផ្អែកលើការព្រមព្រៀងនៃចំណុចទី1។
   - បញ្ជាក់អត្តសញ្ញាណដោយភាគី កាលបរិច្ឆេទ និង ចំនួនទឹកប្រាក់។
   - ចាំបាច់ត្រូវមានចំណុចអំពី ការប្រគល់ប្រាក់ «ដោយផ្អែក» លើការព្រមព្រៀងខ្ចីប្រាក់។
4. ការមកដល់នៃពេលសង
   - ថ្ងៃទី30 ខែ11 ឆ្នាំ2013 បានមកដល់។

# អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ និង ជាមូលហេតុនៃការទាមទារ 1—①ការទាមទារឲ្យសងប្រាក់ដើម 10.000$ (បន្ត)

- ហេតុអ្វីបានជាចាំបាច់ត្រូវអះអាងអង្គហេតុ 4 ខាងលើ ដើម្បីបញ្ជាក់ និងជាមូលហេតុនៃការទាមទារ?
- តើចាំបាច់ត្រូវអះអាងថា Y មិនទាន់បានសងដែរឬទេ?

# អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ និង ជាមូលហេតុនៃការទាមទារ 1－② ការទាមទារការប្រាក់ 15% / ឆ្នាំ

1. ចំណុចទី1~3 នៃអង្គហេតុដែលជាមូលហេតុនៃការកើតឡើងនៃសិទ្ធិទាមទារឲ្យសងប្រាក់ដើម 10.000$

2. ការព្រមព្រៀងបង់ការប្រាក់ជាលាយលក្ខអក្សររបស់ X･Y
   - នៅថ្ងៃទី1 ខែ12 ឆ្នាំ2012 X និង Y បានព្រមព្រៀងគ្នា និងបានធ្វើកិច្ចសន្យាខ្ចីប្រាក់ដែលមានហត្ថលេខារបស់ Y អំពីការភ្ជាប់ការប្រាក់ 15% / ឆ្នាំ នៃប្រាក់កម្ចីនៃចំណុចទី1។

3. ការកន្លងផុតអំឡុងពេលជាក់លាក់មួយ ក្រោយការប្រគល់ប្រាក់
   - ថ្ងៃទី30 ខែ11 ឆ្នាំ2013 បានកន្លងផុត (1ឆ្នាំ ក្រោយពីប្រគល់ប្រាក់)។
   - ការប្រគល់ប្រាក់បានអះអាងរួចហើយ នៅក្នុងការទាមទារឲ្យសងប្រាក់ដើមនៃចំណុចទី3។

- ហេតុអ្វីបានជាត្រូវអះអាងអង្គហេតុខាងលើ?

# អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ និង ជាមូលហេតុនៃការទាមទារ

## 1–③ ការទាមទារការប្រាក់ឃើតយ៉ាវតាមការព្រមព្រៀង ក្រោយហួសពេលកំណត់សង

1. ចំណុចទី1~3 នៃអង្គហេតុដែលជាមូលហេតុនៃការកើតឡើងនៃសិទ្ធិទាមទារឲ្យសងប្រាក់ដើម 10.000$

2. ការព្រមព្រៀងអំពីអត្រាការប្រាក់ឃើតយ៉ាវផ្អែកតាមឯកសាររបស់ X・Y

   - នៅថ្ងៃទី1 ខែ12 ឆ្នាំ2012 X និង Y បានព្រមព្រៀងគ្នា និងបានធ្វើកិច្ចសន្យាខ្ចីប្រាក់ដែលមានហត្ថលេខារបស់ Y អំពីអត្រាការប្រាក់ឃើតយ៉ាវ 20% / ឆ្នាំ ក្រោយពេលកំណត់សងកន្លងហួស នៃប្រាក់កម្ចីនៃចំណុចទី1។

3. ការកន្លងផុតអំឡុងពេលជាក់លាក់មួយ ក្រោយហួសពេលសង

   - (ថ្ងៃទី30 ខែ11 ឆ្នាំ2013 ដែលជាពេលសងបានកន្លងផុត ហើយថ្ងៃទី○ ខែ3 ឆ្នាំ2019 ក៏បានកន្លងផុត។)
   - អង្គហេតុខាងលើនេះគឺជាក់លាក់ ហេតុនេះ ភាគច្រើនគេមិនសរសេរច្បាស់លាស់ទេក្នុងពាក្យបណ្ដឹង។

- ហេតុអ្វីបានជាត្រូវអះអាងអង្គហេតុខាងលើ？

# អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ និង ជាមូលហេតុនៃការទាមទារ
# 2－①ការទាមទារឲ្យសងប្រាក់ 5000$

1. ការព្រមព្រៀងអំពីកម្ចីប្រាក់ X・Y
   - នៅថ្ងៃទី15 ខែ3 ឆ្នាំ2013 X និង Y បានព្រមព្រៀងគ្នាថា X ឲ្យ Y ខ្ចីប្រាក់ចំនួន 5.000$ ហើយ Y នឹងសងប្រាក់នេះមកវិញនៅពេលក្រោយ។
   - បញ្ជាក់អត្តសញ្ញាណដោយ ភាគី កាលបរិច្ឆេទ និង ចំនួនទឹកប្រាក់។
2. ការព្រមព្រៀងអំពីការមិនកំណត់ពេលសងរវាង X・Y
   - នៅថ្ងៃទី15 ខែ3 ឆ្នាំ2013 X និង Y បានព្រមព្រៀងគ្នាអំពីការមិនកំណត់ពេលសងនៃចំណុចទី1។
   - នៅក្នុងកិច្ចសន្យាបរិភោគ ពេលសងគឺជាសារជាតុសំខាន់ ហេតុនេះ ទោះបីជាករណីមិនបានកំណត់ពេលសងក៏ដោយ គេពិចារណាថា ជាចេតនាមិនកំណត់ មិនមែនភ្លេចកំណត់នោះទេ។
3. ការប្រគល់ប្រាក់ X→Y
   - នៅថ្ងៃទី15 ខែ3 ឆ្នាំ2013 X បានប្រគល់ប្រាក់ 5.000$ ឲ្យទៅ Y ដោយផ្អែកលើការព្រមព្រៀងនៃចំណុចទី1។
   - បញ្ជាក់អត្តសញ្ញាណដោយ ភាគី កាលបរិច្ឆេទ និង ចំនួនទឹកប្រាក់។
   - ចាំបាច់ត្រូវមានចំណុចអំពី ការប្រគល់ប្រាក់ «ដោយផ្អែក» លើការព្រមព្រៀងខ្ចីប្រាក់។

# អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ និង ជាមូលហេតុនៃការទាមទារ 2—①ការទាមទារឲ្យសងប្រាក់ 5000$ (បន្ត)

4. ដាស់តឿន X→Y
   - នៅថ្ងៃទី2 ខែ12 ឆ្នាំ2013 X បានដាស់តឿនទៅ Y ឲ្យសងប្រាក់ 5.000$ ដែលបានឲ្យខ្ចីដោយផ្អែកលើការព្រមព្រៀងនៃចំណុចទី1 ក្នុងពេល 3ខែក្រោយ។
5. ការមកដល់ថ្ងៃចុងក្រោយនៃអំឡុងពេលសមរម្យក្រោយការដាស់តឿន
   - ថ្ងៃទី2 ខែ3 ឆ្នាំ2014 ដែលជាថ្ងៃចុងក្រោយនៃអំឡុងពេល 3ខែ គិតចាប់ពីពេលដាស់តឿននៃចំណុចទី4 បានមកដល់។ ដោយឡែក យើងអាចគិតថាអំឡុងពេល 3ខែ ជាអំឡុងពេលសមរម្យ ដោយមើលទៅលើការប្រើប្រាស់ប្រាក់ ចំនួនទឹកប្រាក់ និង ព័តមានលំអិតអំពីកម្ចីនេះ។
   - អំឡុងពេលសមរម្យ គឺជាអំឡុងពេលដែលគិតថាសមល្មម ដោយមើលទៅលើការប្រើប្រាស់ប្រាក់ ចំនួនទឹកប្រាក់ និង ព័តមានលំអិតនៃកិច្ចសន្យាខ្ចីប្រាក់ (យុត្តិសាស្ត្រជប៉ុន)។

- ហេតុអ្វីបានជាត្រូវអះអាងអង្គហេតុទាំង 5នេះ?

# អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ និង ជាមូលហេតុនៃការទាមទារ
## 2−②ការទាមទារការប្រាក់យឺតយ៉ាវក្រោយពេលហួសពេលសង

1. ចំណុចទី1~4 នៃអង្គហេតុដែលជាមូលហេតុនៃការកើតឡើងនៃសិទ្ធិទាមទារឲ្យសងប្រាក់ដើម 5.000$
2. ថ្ងៃចុងក្រោយនៃអំឡុងពេលសមរម្យក្រោយការដាស់តឿនបានកន្លងផុត ហើយអំឡុងពេលជាក់លាក់មួយក៏បានកន្លងផុត
   - ( ថ្ងៃទី2 ខែ3 ឆ្នាំ2014 ដែលជាថ្ងៃចុងក្រោយនៃអំឡុងពេលសមរម្យក្រោយការដាស់តឿនបានកន្លងផុត ហើយថ្ងៃទី○ ខែ3 ឆ្នាំ2019 បានកន្លងផុត។)
   - អង្គហេតុខាងលើនេះគឺជាក់លាក់ ហេតុនេះ ភាគច្រើនគេមិនសរសេរច្បាស់លាស់ទេក្នុងពាក្យបណ្តឹង។

- ហេតុអ្វីបានជាត្រូវអះអាងអង្គហេតុខាងលើ？

# ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ 1 (ប្រាក់កម្ចី10.000$)

1. ការទាមទារឲ្យសងប្រាក់ 10.000$
   - បង្គាប់ឲ្យ Y បងប្រាក់ចំនួន 10.000$ មកឲ្យ X
     - អង្គហេតុនៃការឲ្យខ្ចីប្រាក់ 10.000$ ចុះថ្ងៃទី1 ខែ12 ឆ្នាំ2012 គឺត្រូវសរសេរនៅក្នុង «សេចក្ដីសន្និដ្ឋាន» ចុងក្រោយនៃអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ និង ជាមូលហេតុនៃការទាមទារ។
2. ការទាមទារឲ្យបង់ការប្រាក់ 15% / ឆ្នាំ
   - បង្គាប់ឲ្យ Y បង់ប្រាក់ចំនួន 1.500$ ឲ្យទៅ X
     - ចំពោះអង្គហេតុដែលជាមូលដ្ឋាននៃការគណនាជាប្រាក់ 1.500$ (10.000$ ×15%=1.500$) នេះ គឺត្រូវសរសេរនៅក្នុង «សេចក្ដីសន្និដ្ឋាន» ចុងក្រោយនៃអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ និង ជាមូលហេតុនៃការទាមទារ។
3. ការទាមទារការប្រាក់យឺតយ៉ាវដោយការព្រមព្រៀងដែលហួសពេលសង
   - បង្គាប់ឲ្យ Y បង់ប្រាក់ក្នុងអត្រា 20% ក្នុងមួយឆ្នាំ នៃចំនួនទឹកប្រាក់ 10.000$ គិតចាប់ពីថ្ងៃទី1 ខែ12 ឆ្នាំ2013 រហូតដល់សងគ្រប់ចំនួនទៅឲ្យ X។
     - ចំពោះអង្គហេតុដែលជាការប្រាក់យឺតយ៉ាវតាមការព្រមព្រៀង គឺត្រូវសរសេរនៅក្នុង «សេចក្ដីសន្និដ្ឋាន» ចុងក្រោយនៃអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ និង ជាមូលហេតុនៃការទាមទារ។

# ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ 2 (ប្រាក់កម្ចី 5.000$)

1. ការទាមទារឲ្យសងប្រាក់ដើម 5.000$
   - បង្គាប់ឲ្យ Y បង់ប្រាក់ចំនួន 5.000$ ឲ្យទៅ X
     - អង្គហេតុនៃការឲ្យខ្ចីប្រាក់ 5.000$ ចុះថ្ងៃទី15 ខែ3 ឆ្នាំ2013 គឺត្រូវសរសេរនៅក្នុង «សេចក្ដីសន្និដ្ឋាន» ចុងក្រោយនៃអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ និង ជាមូលហេតុនៃការទាមទារ។
2. ការទាមទារការប្រាក់យឺតយ៉ាវតាមច្បាប់កំណត់ ក្រោយហួសពេលសង
   - បង្គាប់ឲ្យ Y បង់ប្រាក់ក្នុងអត្រា 5% ក្នុងមួយឆ្នាំនៃចំនួនទឹកប្រាក់ 5.000$ ដោយគិតចាប់ពីថ្ងៃទី3 ខែ3 ឆ្នាំ2014 រហូតដល់សងគ្រប់ចំនួនទៅឲ្យ X
     - ចំពោះអង្គហេតុដែលជាការប្រាក់យឺតយ៉ាវតាមច្បាប់ គឺត្រូវសរសេរនៅក្នុង «សេចក្ដីសន្និដ្ឋាន» ចុងក្រោយនៃអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ និង ជាមូលហេតុនៃការទាមទារ។

# ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ 3 (ផ្សេងទៀត)

1. បន្ទុកនៃប្រាក់ប្រដាប់ក្ដី
   - ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។
2. ការសុំឲ្យប្រកាសអនុវត្តជាបណ្ដោះអាសន្ន
   - ទាមទារឲ្យភ្ជាប់ការប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្ន (CCP196 I )។

# តើត្រូវដាក់អ្វីខ្លះធ្វើជាឯកសារភស្តុតាង?

- លិខិតកិច្ចសន្យាខ្ចីប្រាក់
  - ប្រសិនបើមានសរសេរទាំងអស់អំពី ចំនួនទឹកប្រាក់ ពេលកំណត់សង ការប្រាក់ ការប្រាក់ឃឹត នោះឯកសារនេះនឹងក្លាយទៅជាភស្តុតាងអំពីការព្រមព្រៀងទាំងអស់ ដូចជាការព្រមព្រៀងអំពីប្រាក់កម្ចី ការព្រមព្រៀងអំពីពេលសង និងការព្រមព្រៀងអំពីការប្រាក់ ជាអាទិ៍។
- លិខិតទទួលប្រាក់, តារាងផ្ញើប្រាក់ចូលតាមគណនី
  - ឯកសារនេះក្លាយជាភស្តុតាងនៃការប្រគល់ប្រាក់។
- ដល់ពេលសងជាអាទិ៍, កាលបរិច្ឆេទណាមួយមកដល់ ឬ កន្លងផុត
  - ភស្តុតាងគឺមិនចាំបាច់នោះទេ ពីព្រោះវាជាអង្គហេតុដែលតុលាការយល់ច្បាស់

# ឯកសារភ្ជាប់

- លិខិតប្រគល់អំណាត្តិក្នុងបណ្តឹង
- សេចក្តីចម្លងឯកសារភស្តុតាង

# សាកល្បងសេរសេរអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ និងជាមូលហេតុនៃការទាមទារ 1

1. ដើមចោទ និង ចុងចម្លើយបានព្រមព្រៀងគ្នាថា ដើមចោទឲ្យខ្ចីចំនួន 10.000$ នៅថ្ងៃទី1 ខែ12 ឆ្នាំ 2012, ពេលកំណត់សងគឺ ថ្ងៃទី30 ខែ11 ឆ្នាំ2013, ការប្រាក់ 15% ក្នុងមួយឆ្នាំ, ការប្រាក់យឺតយ៉ាវ 20% ក្នុងមួយឆ្នាំ ហើយបានធ្វើកិច្ចសន្យាខ្ចីប្រាក់ដែលមានចុះហត្ថលេខារបស់ Y ដែលបញ្ជាក់ថា Y យល់ព្រមសងតាមខ្លឹមសាខាងលើ។
2. នៅថ្ងៃដដែល ដើមចោទបានប្រគល់ប្រាក់ចំនួន 10.000$ ដោយផ្អែកលើការព្រមព្រៀងនៃចំណុចទី1 ឲ្យទៅចុងចម្លើយ។
3. ថ្ងៃទី30 ខែ11 ឆ្នាំ2013 ដែលជាពេលសងបានមកដល់ (ប៉ុន្តែ រហូតមកដល់ពេលនេះ ចុងចម្លើយមិនបានសងអ្វីទាំងអស់)។
4. ហេតុនេះ ដើមចោទទាមទារឲ្យចុងចម្លើយបង់ប្រាក់ដើម 10.000$ នៃកម្ចីចំណុចទី1, ហើយការប្រាក់ 1.500$ នៃចំនួនប្រាក់ដើមគិតចាប់ពីថ្ងៃទី1 ខែ12 ឆ្នាំ2012 ដល់ថ្ងៃទី30 ខែ11 ឆ្នាំ2013, និងការប្រាក់យឺតយ៉ាវតាមការព្រមព្រៀងក្នុងអត្រា 20% ក្នុងមួយឆ្នាំនៃចំនួនប្រាក់ដើម 10.000$ នៃកម្ចីចំណុចទី1 ដោយគិតចាប់ពីថ្ងៃទី1 ខែ12 ឆ្នាំ2013 ដែលជាថ្ងៃបន្ទាប់ពីពេលសងរហូតដល់សងគ្រប់ចំនួន។

# សាកល្បងសេរសេរអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ និង ជាមូលហេតុនៃការទាមទារ2

1. ដើមចោទ និង ចុងចម្លើយបានព្រមព្រៀងគ្នាថា ដើមចោទឲ្យខ្ចីប្រាក់ចំនួន 5.000$ នៅថ្ងៃទី15 ខែ3 ឆ្នាំ2013 ដោយមិនកំណត់ពេលសង, ហើយ Y ត្រូវសងវិញនៅពេលក្រោយ។
2. នៅថ្ងៃដដែល ដើមចោទបានប្រគល់ប្រាក់ចំនួន 5.000$ ដោយផ្អែកលើការព្រមព្រៀងនៃចំណុចទី1 ទៅចុងចម្លើយ។
3. នៅថ្ងៃទី2 ខែ12 ឆ្នាំ2012 ដើមចោទបានដាស់តឿនឲ្យចុងចម្លើយសងប្រាក់ 5.000$ ដែលបានប្រគល់ដោយផ្អែកលើការព្រមព្រៀងនៃចំណុចទី1 ដោយកំណត់ពេល 3ខែក្រោយ ត្រូវជាថ្ងៃទី2 ខែ3 ឆ្នាំ2014។
4. ថ្ងៃទី2 ខែ3 ឆ្នាំ2014 បានមកដល់។ ដោយឡែក អំឡុងពេល 3ខែ ជាអំឡុងពេលសមរម្យ ដោយមើលទៅលើការប្រើប្រាស់ប្រាក់ ចំនួនទឹកប្រាក់ និង ព័តមានលំអិតអំពីកម្ចីនេះ។ (ប៉ុន្តែ រហូតមកដល់ថ្ងៃនេះ ចុងចម្លើយមិនបានសងអ្វីទាំងអស់)។
5. ហេតុនេះ ដើមចោទទាមទារឲ្យចុងចម្លើយបង់ប្រាក់ 5.000$ នៃកម្ចីចំណុចទី1, ហើយការប្រាក់យឺតយ៉ាវក្នុងអត្រា 5% ក្នុងមួយឆ្នាំនៃចំនួនប្រាក់ដើម ដោយគិតចាប់ពីថ្ងៃទី3 ខែ3 ឆ្នាំ2014 ដែលជាពេលកន្លងហួសរយៈពេល 3ខែ ដែលជាអំឡុងពេលសមរម្យ រហូតដល់ពេលសងគ្រប់ចំនួន។

# សាកល្បងពិចារណាផ្លូវច្បាប់អំពីការលើកឡើងរបស់ចុងចម្លើយ

- «ប្រាក់10.000$ ខ្ញុំមិនបានទទួលទេ»
  - ការបដិសេធការទទួលការប្រគល់ប្រាក់
- «នៅថ្ងៃទី1 ខែ12 ឆ្នាំ2013 ខ្ញុំបានប្រគល់ប្រាក់ចំនួន 11.500$ ទៅឲ្យ X តាមរយៈ A រួចហើយ»
  - ការតវ៉ាដោយការសង
- «ខ្ញុំមិនចាំថា បាននិយាយសុំខ្ចីប្រាក់បន្ថែមពី X ទេ»
  - ការបដិសេធលើការព្រមព្រៀងខ្ចីប្រាក់ ការព្រមព្រៀងលើពេលសង និងការប្រគល់ប្រាក់

# តើការតវ៉ារបស់ចុងចម្លើយមានក្រៅពីនេះទេ ?

1. អាជ្ញាយុកាលនៃការរលត់លើប្រាក់កម្ចី 10.000$
    a. ពេលចាប់ផ្ដើមរាប់អាជ្ញាយុកាល («ពេលដែលអាចអនុវត្តសិទ្ធិលើបំណុលបាន» CC481)
    b. អំឡុងពេលអាជ្ញាយុកាលគឺ 5ឆ្នាំ (CC482)
    c. ត្រូវបង្ហាញឆន្ទៈលើកឡើងអំពីអាជ្ញាយុកាល (CC486)
2. អាជ្ញាយុកាលនៃការរលត់លើប្រាក់កម្ចី 5.000$
    a. ពេលចាប់ផ្ដើមរាប់អាជ្ញាយុកាល
        - ពេលកំណត់សងគឺ ក្រោយអំឡុងពេលសមរម្យបន្ទាប់ពីការដាស់តឿន (CC594 II )
        - ការដាស់តឿនអាចធ្វើឡើងនៅពេលណាក៏បាន (ថ្ងៃដែលប្រគល់ប្រាក់ក៏បានដែរ)
        - ពេលចាប់ផ្ដើមអនុវត្តគឺពីថ្ងៃដែលបានប្រគល់ប្រាក់រហូតដល់ក្រោយពីអំឡុងពេលសមរម្យ
    b. អំឡុងពេលអាជ្ញាយុកាល, ការបង្ហាញសឆន្ទៈលើកឡើង

# តើការតវ៉ាតបរបស់ដើមចោទមានអ្វីខ្លះ ?

- នៅអំឡុងខែ4 ឆ្នាំ2014, សំបុត្រពី Y→X ដែលមានខ្លឹមសារថា «សូមពន្យារពេលសងប្រហែលជា 1ឆ្នាំ»
  - ការទទួលស្គាល់កាតព្វកិច្ច ( CC489③ )
  - ក្លាយជាការផ្អាកអាជ្ញាយុកាលនៃការរលត់